**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ១៩៧០៣/២៤ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសដើម្បីគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈ ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតអនុគណៈកម្មាធិការប្រតិបត្តិ និងក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- យោងតាមការចាំបាច់



ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

## សម្រេច

**ប្រការ១** .-

បង្កើតក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន ចំណុះក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ដូចខាងក្រោម៖

ក. ក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន

១. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យរដ្ឋបាលទូទៅ

២. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៣. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសង្គមកិច្ច

៤. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសេដ្ឋកិច្ច

ខ. ក្រុមការងារបច្ចេកទេសធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន

៥. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យរដ្ឋបាលទូទៅ

៦. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៧. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសង្គមកិច្ច

៨. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសេដ្ឋកិច្ច

៩. ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា

១០. ក្រុមការងារបច្ចេកទេសបណ្តុះបណ្តាល និងគាំទ្រ

ក្រុមការងារបច្ចេកទេសគាំទ្រវិស័យនីមួយៗ ត្រូវបានបែងចែកជាពីរក្រុមគឺ៖

១). ក្រុមជំរុញតាមដាន

២). ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

គ. ក្រុមការងារបច្ចេកទេសគាំទ្ររួម

១១. ក្រុមការងារគាំទ្របច្ចេកទេស

១២. ក្រុមការងារបូកសរុបរួម។

វិស័យរដ្ឋបាលទូទៅ រួមមាន៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន អង្គភាពប្រឆាំងអំពើពុករលួយ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ រួមមាន៖ ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ និងក្រសួងយុត្តិធម៌។

វិស័យសង្គមកិច្ច រួមមាន៖ ក្រសួងព័ត៌មាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា ក្រសួងកិច្ចការនារី និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វិស័យសេដ្ឋកិច្ច រួមមាន៖ ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍

ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ២** .-

ក្រុមការងារបច្ចេកទេសនីមួយៗ ដូចមានកំណត់ក្នុងប្រការ១ មានភារកិច្ចដូចខាងក្រោម៖

ក. ក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន

- ជាជនបង្គោលដើម្បីផ្តល់ការសម្របសម្រួល និងគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ក្នុងវិស័យនីមួយៗ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំ និងរាយការណ៍ជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ដើម្បីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដឹកនាំតម្រង់ទិស
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

ខ. ក្រុមការងារបច្ចេកទេសធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន

ក្រុមជំរុញតាមដាន

- ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពការងារពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន ក្នុងវិស័យនីមួយៗ
- រាយការណ៍ជាប្រចាំជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

- ពិនិត្យ និងអនុម័តទិន្នន័យមន្ត្រីរាជការស៊ីវិល ដែលបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ដោយក្រសួង ស្ថាប័នក្នុងវិស័យនីមួយៗ
- ប្រមូល និងរៀបចំទុកដាក់ឯកសារប្រវត្តិរូបមន្ត្រីរាជការស៊ីវិល ដែលបានបញ្ជូនមកក្រសួងមុខងារសាធារណៈ ដោយក្រសួង ស្ថាប័ន ក្នុងវិស័យនីមួយៗ
- សហការជាមួយលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ដើម្បីរៀបចំ និងទុកដាក់ឯកសារបច្ចុប្បន្នភាពមន្ត្រីរាជការទៅក្នុងសំណុំឯកសាររបស់មន្ត្រីរាជការនីមួយៗ ដែលមានតម្កល់នៅក្នុងបណ្ណាសាររបស់ក្រសួងមុខងារសាធារណៈ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផល នៃការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន ក្នុងវិស័យនីមួយៗ និងរាយការណ៍ជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា

- សម្របសម្រួល និងគាំទ្របច្ចេកទេសផ្នែកព័ត៌មានវិទ្យា ដល់ក្រុមការងារទាំងអស់ពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

ក្រុមការងារបណ្តុះបណ្តាល និងគាំទ្រ

- សម្របសម្រួល គាំទ្រ និងផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារទាំងអស់ពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

គ. ក្រុមការងារបច្ចេកទេសគាំទ្ររួម

ក្រុមការងារគាំទ្របច្ចេកទេស

- ជួយប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ក្នុងការសម្របសម្រួល តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្របច្ចេកទេសដល់គ្រប់ក្រុមការងារបច្ចេកទេស ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងសេចក្តីសម្រេចនេះ
- ជួយប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនិងកិច្ចប្រជុំបច្ចេកទេសផ្សេងៗ លើការរៀបចំខ្លឹមសារ ឧបករណ៍ វិធីសាស្ត្របណ្តុះបណ្តាល និងវាយតម្លៃប្រសិទ្ធភាពបណ្តុះបណ្តាល
- ជួយប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារនៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ក្នុងការផ្តល់យោបល់ និងលើកវិធានការដំណោះស្រាយក្នុងការអនុវត្តការវិភាគមុខងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

ក្រុមការងារបូកសរុបរួម

- បូកសរុបរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំ របស់ក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងក្រុមការងារបច្ចេកទេសធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន និងរាយការណ៍ជូនប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ដើម្បីតាមដាន ត្រួតពិនិត្យ វាយតម្លៃ គាំទ្រ និងដឹកនាំតម្រង់ទិស
- ជួយដល់ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ក្នុងការរៀបចំរបាយការណ៍លទ្ធផលផ្លូវការ នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

**ប្រការ៣** .-

តែងតាំងសមាសភាពក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន ចំណុះក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. ដូចខាងក្រោម៖

**ក. ក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធនៃក្រសួងស្ថាប័ន**

១. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យរដ្ឋបាលទូទៅ

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **តឹក ភុស្សនា** | អគ្គលេខាធិការរង នៃ អ.គ.ក.ស. | ប្រធាន |
| ២- លោក | **លន គីមហេង** | អគ្គនាយករង | អនុប្រធាន |
| ៣- លោក | **ម៉េង ម៉ង់ឌិត** | អគ្គនាយករង | អនុប្រធាន |
| ៤- លោក | **ហែន សារិទ្ធ** | អគ្គាធិការរង | អនុប្រធាន |
| ៥- លោកស្រី | **អ៊ឹម សុវណ្ណារី** | អគ្គនាយករង | សមាជិក |
| ៦- លោក | **គង់តារា ផល្លន** | ប្រធាននាយកដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |
| ៧- លោក | **ចិន សុវណ្ណរិទ្ធិ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៨- លោក | **ឡេង សុភក្ត្រ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៩- លោក | **ជា ឡឿន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១០- លោក | **សៅ សុភត្រ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១១- លោក | **ពីឌូ សុភ័ក្ត្រា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២- លោកស្រី | **ខ្លូង សុជាតា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣- លោកស្រី | **ឌួន ចំណាន** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤- លោក | **វឿន ទ្រី** | មន្ត្រី | សមាជិក |
| ១៥- លោក | **គង់ វ៉ាឌី** | មន្ត្រី | សមាជិក |
| ១៦- លោក | **ឃី ដាវុធ** | មន្ត្រី | សមាជិក |
| ១៧- លោកស្រី | **វុត្ថា កញ្ញាតា** | មន្ត្រី | សមាជិក |
| ១៨- លោក | **ចាន់ លីហេង** | មន្ត្រី | សមាជិក |
| ១៩- លោក | **ម៉េង សុផា** | មន្ត្រី | សមាជិក |
| ២០- លោកស្រី | **ភប ចន្ធូ** | មន្ត្រី | សមាជិក |
| ២១- លោកស្រី | **ផាត ពិសី** | មន្ត្រី | សមាជិក |
| ២២- លោក | **ប្រុស ច័ន្ទសុចិន្តា** | មន្ត្រី | សមាជិក |
| ២៣- លោក | **ហេង ម៉េងលាង** | មន្ត្រី | សមាជិក។ |

២. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **គង់ សុវត្ថិភាព** | អគ្គលេខាធិការរង នៃ អ.គ.ក.ស. | ប្រធាន |
| ២- លោកស្រី | **មាស សម្ផស្ស** | អគ្គនាយករង | អនុប្រធាន |
| ៣- លោក | **មាស ឌួនឃៀង** | អគ្គនាយករង | អនុប្រធាន |
| ៤- លោក | **ទី វ៉ាណាត** | អគ្គាធិការរង | សមាជិកអចិន្ត្រៃយ៍ |
| ៥- លោកស្រី | **ឈុន ពុទ្ធានី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោក | **ហេង លីហាប់** | ប្រធានការិយាល័យ | សមាជិក |
| ៧- លោកស្រី | **ហេង្ស វិទូ** | ប្រធានការិយាល័យ | សមាជិក |
| ៨- លោក | **ប្រិច វ៉ាទី** | មន្ត្រី | សមាជិក |
| ៩- លោកស្រី | **ទាន សុខម៉ូនីកា** | មន្ត្រី | សមាជិក |
| ១០- លោក | **ស៊ុំ រស្មី** | មន្ត្រី | សមាជិក។ |

៣. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសង្គមកិច្ច

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ប្រាក់ ប្រានីដ្ឋា** | អគ្គលេខាធិការរង នៃ អ.គ.ក.ស. | ប្រធាន |
| ២- លោក | **ប៉ែន ពិសិដ្ឋ** | អគ្គនាយករង | អនុប្រធាន |
| ៣- លោក | **តួង ពិទូ** | អគ្គាធិការរង | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៤- | លោកស្រី | **អ៊ិត ផល្លីស** | ប្រធាននាយកដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |
| ៥- | លោក | **ជា ចំរុង** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៦- | លោក | **ផាន់ សុសត្យា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៧- | កញ្ញា | **ប្រាក់ អមរាទេវី** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៨- | លោក | **អោ សំបូរ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៩- | លោក | **ទូច សារឿន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១០- | លោកស្រី | **អន សុម៉ាលី** | ប្រធានការិយាល័យ | សមាជិក |
| ១១- | លោក | **ឆាយ មីត** | ប្រធានការិយាល័យ | សមាជិក |
| ១២- | លោក | **ធិត ឌិម៉ា** | មន្ត្រី | សមាជិក |
| ១៣- | លោក | **ឆេង សារី** | មន្ត្រី | សមាជិក |
| ១៤- | លោក | **ខេង រិទ្ធី** | មន្ត្រី | សមាជិក |
| ១៥- | លោក | **ឆុន នគាល័យ** | មន្ត្រី | សមាជិក |
| ១៦- | លោកស្រី | **សឿន និត្តា** | មន្ត្រី | សមាជិក |
| ១៧- | លោក | **សំ ស៊ីនួន** | មន្ត្រី | សមាជិក |
| ១៨- | លោក | **បូ សុភោគ** | មន្ត្រី | សមាជិក |
| ១៩- | លោកស្រី | **ម៉េត បរមី** | មន្ត្រី | សមាជិក |
| ២០- | លោកស្រី | **ដៃ ផល្លា** | មន្ត្រី | សមាជិក |
| ២១- | លោក | **យន់ ម៉េងហ៊ាង** | មន្ត្រី | សមាជិក។ |

## ៤. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសេដ្ឋកិច្ច

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **សួន រស្មី** | អគ្គលេខាធិការរង នៃ អ.គ.ក.ស. | ប្រធាន |
| ២- | លោក | **ជិន វណ្ណថា** | អគ្គលេខាធិការរង | អនុប្រធាន |
| ៣- | លោក | **ប្រាក់ តា** | អគ្គនាយករង | អនុប្រធាន |
| ៤- | លោក | **សូ វ៉ាង** | អគ្គនាយករង | អនុប្រធាន |
| ៥- | លោក | **សុខ សំណាង** | ប្រធាននាយកដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |
| ៦- | លោក | **ប៊ិច សៀកឡេង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧- | លោក | **កុសល ធារ៉ា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨- | លោក | **លី ថាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៩- | លោកស្រី | **ឆាម ច័ន្ទស្រីនី** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១០- | លោកស្រី | **ឌីណា ស៊ីថាមុនីរ័ត្ន** | អនុប្រធានការិយាល័យ | សមាជិក |
| ១១- | លោក | **សុឃន ប៊ុនហេង** | មន្ត្រី | សមាជិក |
| ១២- | លោក | **ពៅ ចិត្រា** | មន្ត្រី | សមាជិក |
| ១៣- | លោកស្រី | **សោម ចាន់សម្បត្តិ** | មន្ត្រី | សមាជិក |
| ១៤- | លោក | **ហុង គីមឡេង** | មន្ត្រី | សមាជិក |
| ១៥- | លោក | **ដៃ ទិត្យសុគន្ធា** | មន្ត្រី | សមាជិក |
| ១៦- | លោក | **ឃីម សំណាង** | មន្ត្រី | សមាជិក |
| ១៧- | លោកស្រី | **សំអាន សិទ្ធិភារ្យ** | មន្ត្រី | សមាជិក |
| ១៨- | លោក | **ម៉ែល ពន្លក** | មន្ត្រី | សមាជិក |
| ១៩- | លោកស្រី | **ឈេន សុភ័ស្ស** | មន្ត្រី | សមាជិក |
| ២០- | លោកស្រី | **អ៊ូច ច័ន្ទវត្តី** | មន្ត្រី | សមាជិក |
| ២១- | លោក | **គួ មករា** | មន្ត្រី | សមាជិក។ |

ខ. ក្រុមការងារបច្ចេកទេសធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន

៥. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យរដ្ឋបាលទូទៅ

៥.១.ក្រុមជំរុញតាមដាន

| | | | |
|---|---|---|---|
| ១- លោក | **ម៉េង ម៉ង់ឌិត** | អគ្គនាយករង | ប្រធាន |
| ២- លោក | **យិន រុន** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន។ |

៥.២.ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

| | | | |
|---|---|---|---|
| ១- លោកស្រី | **អ៊ុក ទូច** | អគ្គនាយករង | ប្រធាន |
| ២- លោក | **ថ័រ សុផល** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **ស្បោង សម្បត្តិ** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៤- លោក | **ទូច គន្ធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **ឃុច សុភា** | ប្រធានការិយាល័យ | សមាជិក |
| ៦- លោក | **គាំ សុខាន់** | ប្រធានការិយាល័យ | សមាជិក |
| ៧- លោក | **អ៊ិន វីធុរដ្ឋ** | ប្រធានការិយាល័យ | សមាជិក។ |

៦. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៦.១.ក្រុមជំរុញតាមដាន

| | | | |
|---|---|---|---|
| ១- លោក | **ឈុប សុគន្ធា** | អគ្គនាយករង | ប្រធាន |
| ២- លោក | **វ៉េង ឈាត** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន។ |

៦.២.ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

| | | | |
|---|---|---|---|
| ១- លោកស្រី | **សេង សុខេមា** | អនុប្រធាននាយកដ្ឋាន | ប្រធាន |
| ២- លោកស្រី | **អាង ឆៃលីម** | ប្រធានការិយាល័យ | អនុប្រធាន |
| ៣- លោកស្រី | **ថាន់ថាង ដាណែត** | អនុប្រធានការិយាល័យ | សមាជិក |
| ៤- លោកស្រី | **សៅ ច័ន្ទពិសី** | អនុប្រធានការិយាល័យ | សមាជិក |
| ៥- លោកស្រី | **ណី រតនា** | អនុប្រធានការិយាល័យ | សមាជិក។ |

៧. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសង្គមកិច្ច

៧.១.ក្រុមជំរុញតាមដាន

| | | | |
|---|---|---|---|
| ១- លោក | **ម៉ម តឿក** | អគ្គនាយករង | ប្រធាន |
| ២- លោក | **អៀង គីមឈាង** | ប្រធាននាយកដ្ឋាន | អនុប្រធាន។ |

៧.២.ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

| | | | |
|---|---|---|---|
| ១- លោក | **ប្រាក់ តា** | អគ្គនាយករង | ប្រធាន |
| ២- លោក | **សយ វិសាល** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **ស្រី សាធុធ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៤- លោកស្រី | **យ៉េម សុគន្ធារី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **ប៊ុនធឿន ប៊ុនកេដា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោកស្រី | **ឆម ស្រីលីម** | ប្រធានការិយាល័យ | សមាជិក |
| ៧- លោក | **សម្បត្តិ ឧត្តម** | ប្រធានការិយាល័យ | សមាជិក។ |

### ៨. ក្រុមការងារបច្ចេកទេសគាំទ្រវិស័យសេដ្ឋកិច្ច

#### ៨.១.ក្រុមជំរុញតាមដាន

| | | | |
|---|---|---|---|
| ១- លោក | **មាស ពេជ្រ** | អគ្គនាយករង | ប្រធាន |
| ២- លោកស្រី | **ផេង សេរីរតនា** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន។ |

#### ៨.២.ក្រុមត្រួតពិនិត្យ និងទុកដាក់ឯកសារ

| | | | |
|---|---|---|---|
| ១- លោក | **យ៉ង់ មណីរ័ត្ន** | អគ្គនាយករង | ប្រធាន |
| ២- លោក | **ហេង គីមស៊ាន** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **អ៊ាន សុខៃ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៤- លោកស្រី | **សំ សុគា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **សេង រដ្ឋា** | ប្រធានការិយាល័យ | សមាជិក |
| ៦- លោកស្រី | **ខ្លួន ចំណាន** | អនុប្រធានការិយាល័យ | សមាជិក |
| ៧- លោក | **អ៊ុំ ចាន់ស៊ុ** | អនុប្រធានការិយាល័យ | សមាជិក។ |

### ៩. ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា

| | | | |
|---|---|---|---|
| ១- លោក | **ឆិត ដារ៉ា** | ប្រធាននាយកដ្ឋាន | ប្រធាន |
| ២- លោក | **លី ចាន់ណា** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **តាង គីមហាប់** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៤- លោក | **ហោ ស៊ីណាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **គាំ ឌុទ្ធា** | អនុប្រធាននាយកដ្ឋាន | សមាជិក។ |

### ១០. ក្រុមការងារបច្ចេកទេសបណ្តុះបណ្តាល និងគាំទ្រ

| | | | |
|---|---|---|---|
| ១- លោក | **ខន់ ម៉ុរ** | អគ្គនាយករង | ប្រធាន |
| ២- លោក | **លី ចាន់ណា** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣- លោក | **តាង គីមហាប់** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៤- លោក | **ហោ ស៊ីណាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **គាំ ឌុទ្ធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោក | **ថ័រ ឆុន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧- លោក | **ស៊ីម សីហា** | ប្រធានការិយាល័យ | សមាជិក |
| ៨- លោកស្រី | **ពៅ មករា** | ប្រធានការិយាល័យ | សមាជិក |
| ៩- លោក | **វណ្ណា ឡាហ្វី** | មន្ត្រី | សមាជិក |
| ១០- លោក | **ហ៊ើល សម្បូរ** | មន្ត្រី | សមាជិក។ |

## គ. ក្រុមការងារគាំទ្ររួម

### ១១. ក្រុមការងារគាំទ្របច្ចេកទេស

| | | | |
|---|---|---|---|
| ១- លោក | **លន គីមហេង** | អគ្គនាយករង | ប្រធាន |
| ២- លោក | **មាស ពេជ្រ** | អគ្គនាយករង | អនុប្រធាន |
| ៣- លោក | **ខន់ ម៉ុរ** | អគ្គនាយករង | អនុប្រធាន |
| ៤- លោកស្រី | **អ៊ុត ផល្លីស** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៥- លោក | **ឈី នរិន្ទ** | ជំនួយការ | សមាជិក |
| ៦- លោក | **សាន្ត សុខហេង** | មន្ត្រី | សមាជិក |
| ៧- លោកស្រី | **តួង សុធារី** | មន្ត្រី | សមាជិក |
| ៨- លោក | **ឆា ប៉ុន្ឡេន** | មន្ត្រី | សមាជិក |
| ៩- លោកស្រី | **ជួន អមរា** | មន្ត្រី | សមាជិក។ |

១៧. ក្រុមការងារបុកសរុបរួម

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សួន រស្មី** | អគ្គលេខាធិការរង នៃ អ.គ.ក.ស. | ប្រធាន |
| ២- លោក | **ជិន វណ្ណថា** | អគ្គលេខាធិការរង | អនុប្រធាន |
| ៣- លោក | **សុខ សំណាង** | ប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៤- លោក | **កុសល ឆាវ៉ា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក | **លី ថាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោកស្រី | **ឆាម ច័ន្ទស្រីនី** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៧- លោកស្រី | **ឌីណា ស៊ីថាមុនីរ័ត្ន** | អនុប្រធានការិយាល័យ | សមាជិក |
| ៨- លោក | **សុឃន ម៉ិនហេង** | មន្ត្រី | សមាជិក |
| ៩- លោកស្រី | **ធី ច័ន្ទលីណា** | មន្ត្រី | សមាជិក |
| ១០- លោក | **ឃឹម ហ្គេចហេង** | មន្ត្រី | សមាជិក។ |

**ប្រការ៤ .-**

ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក នៃក្រុមការងារបច្ចេកទេសគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារនៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.។

អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក នៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសនីមួយៗ។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ នាយកសាលាភូមិន្ទរដ្ឋបាល អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគ.ក.ស. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាអនុប្រធានប្រចាំការនៃ គ.វ.រ**

ហ៊ុន ម៉ានី

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ដូចប្រការ៥

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ កាលប្បវត្តិ